# ថ្នាំបង្ការជំងឺ COVID-19 - សំណួរដែលបានសួរជាញឹកញាប់ ដូសជំរុញ

ដើម្បីមើលសំណួរទាំងនេះ និងសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀតទាក់ទងនឹងថ្នាំបង្ការ តាមអនឡាញ សូមចូលទៅកាន់ គេហទំព័រអំពីថ្នាំបង្ការជំងឺ COVID-19។

## ហេតុអ្វីបានដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 មានសារៈសំខាន់?

មានការប្រើប្រាស់ដូសជំរុញសម្រាប់ថ្នាំបង្ការជាច្រើនប្រភេទ ដើម្បីផ្តល់នូវប្រព័ន្ធការពារបន្តទៀត ប្រឆាំងនឹងការឆ្លងជំងឺកម្រិតធ្ងន់ធ្ងរ។

ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ បន្តដំណើរការបានល្អ ក្នុងការការពារមនុស្សនានាពីការឆ្លងជំងឺកម្រិតធ្ងន់ធ្ងរ។ ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃប្រព័ន្ធការពារអាចមានការចុះទន់ខ្សោយ ទៅតាមពេលវេលា។ ការទទួលចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 មានសារៈសំខាន់ ពីព្រោះដូសជំរុញនេះជួយពង្រឹងប្រព័ន្ធភាពស៊ាំរបស់អ្នក។ ការធ្វើបែបនេះផ្តល់ជូននូវប្រព័ន្ធការពារដែលប្រសើរជាងមុនដល់អ្នកពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ការត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ហើយនិងសូម្បីតែការស្លាប់ផងដែរ។

សូមទទួលចាក់ដូសជំរុញណាដែលមានការណែនាំសម្រាប់ឱ្យអ្នកចាក់ (សូមមើលផ្នែកខាងក្រោម)។

## តើដូសជំរុញសម្រាប់ជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញ គឺជាអ្វី?

ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (updated booster) ក៏ត្រូវបានស្គាល់ថាជាដូសជំរុញ “បែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន” (bivalent)។ នេះគឺជាថ្នាំបង្ការដែលបានកែប្រែដើម្បីប្រឆាំងដោយផ្ទាល់ទៅនឹងពូជដើមនៃមេរោគ COVID-19 ក៏ដូចជាមេរោគប្រភេទ Omicron BA.4 និង BA.5 ផងដែរ។

ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញអាចជួយធ្វើឱ្យប្រព័ន្ធការពារប្រឆាំងនឹងមេរោគ COVID-19 ដែលបានថយចុះទៅតាមពេលវេលានោះ មានភាពដូចដើមឡើងវិញ។ ដូសជំរុញទាំងនេះក៏អាចផ្តល់ប្រព័ន្ធការពារដែលទូលំទូលាយជាងមុន ប្រឆាំងនឹងប្រភេទមេរោគថ្មីៗ ផងដែរ។

ដូសជំរុញប្រភេទ Pfizer និងប្រភេទ Moderna ទាំងអស់គឺជាថ្នាំបង្ការដែលបានធ្វើឱ្យថ្មីឡើងវិញ (បែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent)។ ដូសជំរុញប្រភេទ Pfizer និងប្រភេទ Moderna ដើម (បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent) គឺលែងមានសម្រាប់ប្រើប្រាស់ហើយ។ ដូសជំរុញប្រភេទ Novavax គឺជាថ្នាំបង្ការដើម  (បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent)។

## តើបុគ្គលណាខ្លះ គួរតែទទួលចាក់ដូសជំរុញសម្រាប់ជំងឺ COVID-19?

មានការណែនាំឱ្យបុគ្គលគ្រប់រូបដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (បែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន) (bivalent) ដោយមានការលើកលែងមួយចំណុច។ កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ ហើយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Pfizer មិនមានសិទ្ធិអាចទទួលចាក់ដូសជំរុញទេ នាពេលនេះ។

មានការណែនាំឱ្យទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញ (updated booster) ចំនួនមួយដូស ក្នុងរយៈពេលយ៉ាងហោចណាស់ 2 ខែ បន្ទាប់ពីបានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដូសចុងក្រោយបង្អស់ (មិនថានោះជាដូសលំដាប់ដំបូង ឬដូសជំរុញដើម [បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន] [monovalent] ចុងក្រោយបង្អស់នោះទេ)។ ការចាក់បែបនេះគឺមិនគិតអំពី ថាតើអ្នកបានទទួលចាក់ដូសជំរុញដើម ( បែប ប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent) ប៉ុន្មានដូសហើយ ឬបានទទួលចាក់ថ្នាំបង្ការប្រភេទណា (មួយ ឬច្រើន) ពីពេលកន្លងមកនោះទេ។ កុមារទាំងឡាយដែលមានអាយុចាប់ពី 11 ចុះក្រោម ទទួលចាក់ដូសជំរុញដែលធ្វើឱ្យថ្មីឡើងវិញនេះ ក្នុងកម្រិតតិចជាងដូសសម្រាប់យុវវ័យ និងមនុស្សពេញវ័យ។

*អាយុចាប់ពី 5 ឆ្នាំឡើងទៅ*

- កុមារទាំងឡាយដែលមានអាយុ 5 ឆ្នាំ ហើយដែលបានបញ្ចប់ការចាក់លំដាប់ដំបូងប្រភេទ Moderna អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Pfizer ឬប្រភេទ Moderna ក៏បាន។
- កុមារទាំងឡាយដែលមានអាយុ 5 ឆ្នាំ ហើយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Pfizer អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Pfizer។
- កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ឆ្នាំឡើងទៅ អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Pfizer ឬប្រភេទ Moderna ក៏បាន។

*អាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ*

- កុមារទាំងឡាយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Moderna អាចទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Moderna។
- កុមារទាំងឡាយដែលបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូងប្រភេទ Pfizer មិនមានសិទ្ធិទទួលចាក់ដូសជំរុញទេ នាពេលនេះ។ កំណត់សម្គាល់៖ លំដាប់ដំបូងប្រភេទ Pfizer សម្រាប់ក្រុមអាយុនេះ រាប់បញ្ចូលថ្នាំបង្ការបែប ប្រឆាំងនឹងមេរោគពីរប្រភេទ/បាយវ៉ាលិន (bivalent) (បែបដែលបានធ្វើឱ្យថ្មីឡើងវិញ) សម្រាប់ដូសទី 3 ហើយ នាពេលឥឡូវនេះ។

***ជម្រើសដូសជំរុញផ្សេងទៀត សម្រាប់បុគ្គលជាក់លាក់មួយចំនួនដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ***

បុគ្គលទាំងឡាយដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ អាចទទួលចាក់ថ្នាំបង្ការប្រភេទ Novavax (បែបប្រឆាំងនឹងមេរោគតែមួយប្រភេទ/ម៉ូណូវ៉ាលិន) (monovalent) ជាដូសជំរុញបាន ជាជាងការទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញប្រភេទ Pfizer ឬក៏ប្រភេទ Moderna តាមការណែនាំនោះ ប្រសិនបើពួកគេស្របតាមលក្ខខ័ណ្ឌទាំងអស់ខាងក្រោមនេះ៖

1. ពួកគេមិនអាច ឬមិនចង់ទទួលចាក់ដូសជំរុញដែលបានធ្វើឱ្យថ្មីឡើងវិញណាមួយ (ឧទាហរណ៍ ប្រសិនបើពួកគេមានប្រតិកម្ម ឬការទាស់កម្រិតធ្ងន់ធ្ងរទៅនឹងថ្នាំបង្ការប្រភេទ mRNA របស់ Pfizer ឬ Moderna នោះ) និង
2. ពួកគេបានបញ្ចប់ការចាក់ថ្នាំបង្ការលំដាប់ដំបូង ហើយនិង
3. ពួកគេមិនដែលបានទទួលចាក់ដូសជំរុញណាមួយ នាពេលកន្លងមកនោះទេ។

មានការផ្តល់ជូនថ្នាំបង្ការប្រភេទ Novavax ក្នុងរយៈពេលយ៉ាងហោចណាស់ 6 ខែបន្ទាប់ពីបានបញ្ចប់ការចាក់ដូសចុងក្រោយបង្អស់សម្រាប់លំដាប់ដំបូង។

**សូមចូលទៅកាន់ទំព័រ *ស្វែងយល់អំពីពេលដែលអាចទទួលចាក់ដូសជំរុញបាន (Find Out When to Get a Booster)* ដែលអាចផ្លាស់ប្តូរព័ត៌មានគ្នាបាន នៅលើគេហទំព័រ ធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយនៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលា រួមទាំងដូសជំរុញ របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ដើម្បីពិនិត្យមើល ថាតើអ្នក (ឬកូនរបស់អ្នក) អាចទទួលចាក់ដូសជំរុញបាននៅពេលណា។**

សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។

## តើខ្ញុំអាចទទួលចាក់ដូសជំរុញបានដែរឬទេ ប្រសិនបើខ្ញុំធ្លាប់មានជំងឺ COVID-19?

ចាស/បាទ អ្នកគួរតែទទួលចាក់ដូសជំរុញ ប្រសិនបើអ្នកធ្លាប់មានជំងឺ COVID-19 រួចហើយនោះ។ មានការណែនាំឱ្យអ្នកធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ រួមទាំងដូសជំរុញ នៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលា បើទោះបីជាអ្នកបានកើតមានជំងឺ COVID-19 រួចហើយក៏ដោយ។ ការធ្វើបែបនេះគឺពីព្រោះតែថ្នាំបង្ការទាំងឡាយដល់នូវប្រព័ន្ធការពារខ្ពស់ជាងមុន។

**ប្រសិនបើអ្នកធ្លាប់មានជំងឺ COVID-19 នាពេលថ្មីៗនេះ**

អ្នកអាចនឹងពិចារណាលើការពន្យារពេលចាក់ដូសថ្នាំបង្ការបន្ទាប់ (ដូសលំដាប់ដំបូង ឬដូសជំរុញ) រហូតដល់រយៈពេល 3 ខែក្រោយ គិតចាប់តាំងពីពេលដែលរោគសញ្ញានានារបស់អ្នកចាប់ផ្តើមលេចចេញ ឬក៏នៅពេលដែលអ្នកធ្វើតេស្តទទួលលទ្ធផលវិជ្ជមានជាលើកដំបូង (ប្រសិនបើអ្នកមិនមានរោគសញ្ញានានាទេ)។ ហានិភ័យរបស់អ្នកនៃការឆ្លងជំងឺនេះម្តងទៀតនោះ គឺមិនសូវទំនងជាខ្ពស់នោះទេ នៅក្នុងអំឡុងពេលពីរឬបីខែដំបូង បន្ទាប់ពីការឆ្លងជំងឺ COVID-19 នាពេលថ្មីៗរួច។ គម្លាតពេលកាន់តែវែងរវាងការឆ្លងមេរោគ និងការទទួលចាក់ថ្នាំបង្ការ ក៏អាចនឹងធ្វើឱ្យការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំកាន់តែប្រសើរផងដែរ។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនគួររង់ចាំចាក់ដូសនោះលើសពីរយៈពេល 3 ខែនោះទេ ហើយការទទួលចាក់ថ្នាំបង្ការឱ្យបានកាន់តែឆាប់ គឺមានសុវត្ថិភាពផងដែរ។

**ប្រសិនបើអ្នកមានជំងឺ COVID-19 នាពេលឥឡូវនេះ**

អ្នកគួរតែរង់ចាំយ៉ាងហោចណាស់រហូតដល់ពេលដែលអ្នកបានបញ្ចប់ការដាក់ខ្លួនឱ្យនៅដាច់ដោយឡែក មុនពេលទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។ ការធ្វើបែបនេះគឺដើម្បីកុំឱ្យអ្នកចម្លងមេរោគ COVID-19 បន្តទៅដល់បុគ្គលិកផ្នែកថែទាំសុខភាព និងអ្នកដទៃទៀត នៅពេលដែលអ្នកទៅទទួលចាក់ថ្នាំបង្ការនោះ។

## តើការទទួលចាក់ដូសជំរុញប្រឈមនឹងហានិភ័យអ្វីខ្លះ?

ប្រតិកម្មផ្សេងៗបន្ទាប់ពីការទទួលចាក់ដូសជំរុញ គឺដូចគ្នាទៅនឹងប្រតិកម្មទាំងឡាយក្រោយការទទួលចាក់ថ្នាំបង្ការដូសដំបូងៗផងដែរ។ ផលប៉ះពាល់ភាគច្រើន គឺមានកម្រិតស្រាលទៅមធ្យម ហើយមានរយៈពេល 2 ថ្ងៃ ឬតិចជាងនេះ។

ដូចគ្នាទៅនឹងលំដាប់ដំបូងផងដែរនោះ ផលប៉ះពាល់កម្រិតធ្ងន់ធ្ងរផ្សេងៗ គឺកម្រនឹងកើតមាន។ សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមចូលទៅកាន់គេហទំព័រស្ដីពី សុវត្ថិភាពនៃថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។ អត្ថប្រយោជន៍នៃការចាក់ដូសជំរុញ គឺមានច្រើនជាងហានិភ័យដែលបានដឹង និងទំនងជាកើតមាន។

## តើខ្ញុំនឹងត្រូវការបង្ហាញកំណត់ត្រា ឬវេជ្ជបញ្ជារបស់គ្រូពេទ្យ ដើម្បីទទួលចាក់ដូសជំរុញ ដែរឬទេ?

ទេ អ្នកមិនត្រូវការកំណត់ត្រា ឬវេជ្ជបញ្ជារបស់គ្រូពេទ្យដើម្បីទទួលចាក់ដូសជំរុញទេ។ នៅពេលដែលអ្នកធ្វើដំណើរទៅទីតាំងនោះ សូមនាំយកភស្តុតាងនៃការចាក់ថ្នាំបង្ការដូចជាកាតពណ៌ស របស់អ្នកដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) ឬកំណត់ត្រានៃការចាក់ថ្នាំបង្ការជាលក្ខណៈឌីជីថលទៅជាមួយ។ សូមចូលទៅកាន់គេហទំព័រ វិធីទទួលចាក់ថ្នាំបង្ការ របស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health) សម្រាប់ព័ត៌មានបន្ថែម។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅទីណា?

- ដើម្បីបោះពុម្ព ឬមើលសំណួរដែលបានសួរជាញឹកញាប់នេះ ឬសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀតទាក់ទងនឹងប្រធានបទថ្នាំបង្ការជំងឺ COVID-19 សូមស្កេនកូដ QR នេះ ឬចូលទៅកាន់គេហទំព័រ សំណួរដែលបានសួរជាញឹកញាប់ទាក់ទងនឹងថ្នាំបង្ការជំងឺ COVID-19។
- គេហទំព័រ ធ្វើឱ្យថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយ នៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលា រួមទាំងដូសជំរុញ របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។
- គេហទំព័រ VaccinateLACounty.com – រួមទាំងគេហទំព័រ កាលវិភាគនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលមានរូបភាពក្រាហ្វិកដើម្បីបង្ហាញនូវពេលណាដែលដូសនីមួយៗដល់ពេលកំណត់អាចទទួលបាន និងព័ត៌មានស្តីពី វិធីទទួលចាក់ថ្នាំបង្ការ។
- សូមពិគ្រោះជាមួយនឹងគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។